ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ០១/១១-ពូ យៀន**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ **សេង វួចហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ **វ៉ែន ពៅ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ពូ យៀន (ខេមបូឌា) អេនធើប្រាយ**

អាសយដ្ឋាន : សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៤៣៤ ៤៨៩ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក Roger Shih | អ្នកគ្រប់គ្រងទូទៅ |
| ២- លោក សោម សំអាត | ប្រធានរដ្ឋបាល |
| ៣- កញ្ញា សុខ ផេង | រដ្ឋបាល |
| ៤- លោក Gan Jian | រដ្ឋបាល |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ : **- សហព័ន្ធសហជីពយុវជនខ្មែរ**

**- សហជីពយុវជនខ្មែរ ក្រុមហ៊ុន ពូ យៀន**

អាសយដ្ឋាន : ភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ◈ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org ◈ Website: www.arbitrationcouncil.org

លេខទូរស័ព្ទ : ០១២ ៩៤០ ៥៤៨ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក ម៉ៃ វឌ្ឍនា | អនុប្រធានសហព័ន្ធសហជីពយុវជនខ្មែរ |
| ២- លោក សៀ សន | មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ |
| ៣- លោក អ៊ិន អ៊ីង | ប្រធានសហជីពយុវជនខ្មែរ ប្រចាំរោងចក្រ |
| ៤- លោក ឡឿន យិន | អនុប្រធានសហជីពយុវជនខ្មែរ ប្រចាំរោងចក្រ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយសំរាប់ធ្វើការបន្ថែមម៉ោង ជូនកម្មករនិយោជិតក្នុងមួយថ្ងៃម្តង ។ ដោយឡែកភាគីក្រុមហ៊ុនសុំអនុវត្តតាមគោលការណ៍ចាស់ ។

២- កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលគោលចំនួន ៨៦ ដុល្លារ ចំពោះកម្មករដែលមានជំនាញផ្នែកជាង និងជាងគ្រប់ជំនាញ ។ ដោយឡែកភាគីក្រុមហ៊ុនសុំអនុវត្តតាមគោលការណ៍ចាស់ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ (អាណត្តិទី៨) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០១១ កប/អក/វក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១១ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១១ (វេលាម៉ោង ០៨:០០ នាទី ព្រឹក) ។

THE ARBITRATION COUNCIL

**បញ្ហានៃនីតិវិធីៈ**

នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងពីសហព័ន្ធសហជីពយុវជនខ្មែរ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារ ដល់ទីតាំងក្រុមហ៊ុន ដោយទទួលលទ្ធផលមិនសះជានឹងគ្នាចំនួន ០២ ចំណុច លើការទាមទារចំនួន ១០ ចំណុច។ ចំណុចមិនសះជាចំនួន ០២ ចំណុចនេះត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ០២ ចំណុចនេះ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ វេលាម៉ោង ០៨:០០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចវិវាទចំនួន ០២ ចំណុចនេះបន្ថែមទៀត ហើយជាលទ្ធផលភាគីកម្មករនិយោជិតបានយល់ព្រមដកចំណុចវិវាទទី២ ចេញពីការទាមទារ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាតែលើចំណុចវិវាទទី១ ប៉ុណ្ណោះ ដោយផ្អែកលើភស្តុតាង និងហេតុផលដូចខាងក្រោមៈ

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតប្រគល់សិទ្ធិរបស់ប្រធានក្រុមហ៊ុន ពូ យៀន ប្រគល់សិទ្ធិជូនលោក សោម សំអាត និងឈ្មោះ សុខ ផេង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១១។

២- លិខិតលេខ ៤៣៨ ស.ស.យ.ខ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ របស់សហព័ន្ធសហជីពយុវជនខ្មែរ គោរពជូន លោកនាយកក្រុមហ៊ុន ពូ យៀន ស្តីពីការជូនដំណឹងស្តីពីការបោះឆ្នោតផ្លាស់ប្តូរគណៈកម្មាធិការសហជីពយុវជនខ្មែរ ប្រចាំក្រុមហ៊ុន ពូ យៀន។

៣- លិខិតលេខ ៤០៦ ស.ស.យ.ខ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ របស់សហព័ន្ធសហជីពយុវជនខ្មែរ គោរពជូន លោកនាយកក្រុមហ៊ុន ពូ យៀន ស្តីពីការជូនដំណឹងស្តីពីការបោះឆ្នោតផ្លាស់ប្តូរគណៈកម្មាធិការសហជីពយុវជនខ្មែរ ប្រចាំក្រុមហ៊ុន ពូ យៀន។

៤- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពយុវជនខ្មែរ ក្រុមហ៊ុន ពូ យៀន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ពូ យៀន (ខេមបូឌា) អេនធើប្រាយ ចុះបញ្ជិកាលេខ ០៥៤ កប/អក/អធក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១០។

៦- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ពូ យៀន (ខេមបូឌា) អេនធើប្រាយ លេខ ១៩៩៥ ពណ.ចបព ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០។

៧- ប័ណ្ណប៉ាតង់របស់ក្រុមហ៊ុន ពូ យៀន (ខេមបូឌា) លេខ DLT 031192.2010 ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១០។

៨- លក្ខន្តិកៈក្រុមហ៊ុន ពូ យៀន (ខេមបូឌា) អេនធើប្រាយ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពយុវជនខ្មែរ ក្រុមហ៊ុន ពូ យៀន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០។

២- លិខិតលេខ ៤៣៨ ស.ស.យ.ខ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ របស់សហព័ន្ធសហជីពយុវជនខ្មែរ គោរពជូន លោកនាយកក្រុមហ៊ុន ពូ យៀន ស្ដីពីការជូនដំណឹងស្ដីពីការបោះឆ្នោតផ្លាស់ប្ដូរគណៈកម្មាធិការសហជីពយុវជនខ្មែរ ប្រចាំក្រុមហ៊ុន ពូ យៀន។

៣- លក្ខន្តិកៈសហជីពយុវជនខ្មែរ ក្រុមហ៊ុន ពូយៀន ចុះបញ្ជិកាលេខ ១៩៦១ កប/វក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

១- របាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ពូយៀន លេខ ០១១ កប/អក/វក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ពូយៀន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ០១២ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ០១៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្ដាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន ពូ យៀន ចាប់ដំណើរការអាជីវកម្មរបស់ខ្លួននៅខែឧសភា ឆ្នាំ២០១០។ បច្ចុប្បន្ន ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិត សរុបប្រមាណ ២២០០ នាក់។
- សហជីពយុវជនខ្មែរ ប្រចាំក្រុមហ៊ុន គឺភាគីជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពនេះ បាន ទទួលវិញ្ញាបនបត្រ័បញ្ជិកា នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០។
- សហជីពយុវជនខ្មែរ មានសមាជិកចំនួន ២៥០ នាក់។ ប៉ុន្តែ ចំពោះការកាត់ប្រាក់ទានសហជីពតាមរយៈ ក្រុមហ៊ុន គឺមានសមាជិកចំនួនតែ ១៤០ នាក់ ប៉ុណ្ណោះ។

**ចំណុចវិវាទទី ១ : កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយសម្រាប់ធ្វើការបន្ថែមម៉ោងជូន កម្មករនិយោជិត ក្នុងមួយថ្ងៃម្តង**

- ភាគីកម្មករនិយោជិត និងនិយោជក បានឯកភាពគ្នាថា ការងារបន្ថែមម៉ោង គឺធ្វើចាប់ពីម៉ោង ៤:០០ ដល់ ម៉ោង ៦:០០ ដោយនិយោជកផ្តល់ជូនប្រាក់ថ្លៃបាយ ចំនួន ១០០០ រៀល ហើយការងារបន្ថែមម៉ោងនេះ អាចមានបន្ត ចាប់ពីម៉ោង ៦:០០ ដល់ម៉ោង ៨:០០ យប់ តទៀត ហើយនិយោជកក៏បានផ្តល់ជូនប្រាក់ ចំនួន ១០០០ រៀលបន្ថែមទៀតផងដែរ។
- ជាទូទៅ ការងារបន្ថែមម៉ោង ពីម៉ោង ៤:០០ ដល់ម៉ោង ៦:០០ គឺមានជារៀងរាល់ថ្ងៃ ហើយកម្មករ និយោជិតទូទាំងរោងចក្រស្ម័គ្រចិត្តធ្វើទាំងអស់គ្នា។ ចំពោះការងារបន្ថែមម៉ោង ដែលបន្តពីម៉ោង ៦:០០ ដល់ម៉ោង ៨:០០ យប់ ពុំសូវមានជារៀងរាល់ថ្ងៃទេ គឺអាចមានត្រឹមពី ៣ ទៅ ៤ ថ្ងៃ ក្នុងមួយអាទិត្យ ប៉ុណ្ណោះ។
- ចំពោះប្រាក់ថ្លៃបាយសម្រាប់ធ្វើការបន្ថែមម៉ោងនេះ និយោជកបើកជូនកម្មករនិយោជិតមួយខែម្តងជាមួយ នឹងថ្ងៃបើកប្រាក់ឈ្នួល គឺនៅរៀងរាល់ថ្ងៃទី ០៨ នៃខែនីមួយៗ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់ថ្លៃបាយ សម្រាប់ធ្វើ ការបន្ថែមម៉ោង ក្នុងមួយថ្ងៃម្តង ដោយមានមូលហេតុថា កម្មករនិយោជិតត្រូវការប្រាក់មកផ្គត់ផ្គង់ សម្រាប់ទិញអាហារមកបរិភោគ នៅពេលធ្វើការបន្ថែមម៉ោងនោះទេ។ ម្យ៉ាងទៀត ប្រកាសលេខ ០១៧ ពុំអនុញ្ញាតឱ្យបើកប្រាក់ថ្លៃបាយនេះ ជូនមួយខែម្តងទេ បើយោងតាមផ្លូវច្បាប់ គឺតម្រូវឱ្យនិយោជកបើក ប្រាក់ថ្លៃបាយនេះ ជារៀងរាល់ថ្ងៃ ព្រោះ កម្មករនិយោជិតត្រូវការបរិភោគបាយរាល់ថ្ងៃដែរ។ ជាទូទៅ កម្មករនិយោជិតមានជីវភាពខ្វះខាត ពួកគាត់ពុំមានប្រាក់គ្រប់គ្រាន់ សម្រាប់ទិញអាហារបរិភោគទេ ហើយពេលខ្លះ ពួកគាត់អាចឈឺ អាចសន្លប់ ឬខ្យល់គ នៅពេលកំពុងធ្វើការ ដោយសារខ្វះជីវជាតិ។
- ភាគីនិយោជកបានលើកឡើងថា និយោជកពុំអាចបើកជូនតាមការទាមទារនេះទេ ពីព្រោះចំនួនកម្មករ និយោជិតច្រើន ហើយការងារថែមម៉ោងនេះ មានជារៀងរាល់ថ្ងៃ ក្រុមហ៊ុនពុំមានបុគ្គលិកគ្រប់គ្រាន់ដើម្បី

មករៀបចំទេ។ម្យ៉ាងទៀត ប្រពន្ធ័គណនេយ្យរបស់ក្រុមហ៊ុន បានបញ្ចូលប្រាក់ឈ្នួល និងប្រាក់បន្ថែមម៉ោងនេះជាមួយគ្នារួចហើយ ក្រុមហ៊ុនពិបាកនឹងធ្វើការកែប្រែណាស់។ ទន្ទឹមនឹងនេះដែរ កន្លងមកក្រុមហ៊ុនពុំដែលទទួលបានបណ្ដឹងតវ៉ាពីកម្មករនិយោជិតផ្ទាល់ ក្នុងការទាមទារនេះទេ។

- ភាគីកម្មករនិយោជិតទាមទារបើកប្រាក់ថ្លៃបាយសម្រាប់ធ្វើការបន្ថែមម៉ោងក្នុងមួយថ្ងៃម្ដងនេះ គឺសម្រាប់កម្មករនិយោជិតទាំងអស់ នៅក្នុងរោងចក្រ។ ប៉ុន្តែ ភាគីសហជីពពុំបានដាក់លិខិតផ្ទេរសិទ្ធិរបស់កម្មករនិយោជិតដែលមិនមែនជាសមាជិករបស់ខ្លួន ដែលបានទាមទារក្នុងចំណុចនេះ ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ ។

**ហេតុផលនៃសេចក្ដីសម្រេចៈ**

**ចំណុចវិវាទទី ១ : កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយសម្រាប់ធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិត ក្នុងមួយថ្ងៃម្ដង**

ក្នុងករណីនេះ ភាគីសហជីពយុវជនខ្មែរ ប្រចាំក្រុមហ៊ុន បានទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិត ក្នុងមួយថ្ងៃម្ដង ហើយបានទាមទារសម្រាប់កម្មករនិយោជិតទាំងអស់នៅក្នុងរោងចក្រ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា ដូចតទៅៈ

ប្រការ ១៩ នៃប្រកាសលេខ ៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាល ដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម.. .ឬ ដោយបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ពីភាគីនោះ"* ។

តាមខ្លឹមសារប្រការ ១៩ នៃប្រកាសលេខ ៩៩ សកបយ ខាងលើ មានន័យថា នៅក្នុងសវនាការអាជ្ញាកណ្ដាល ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាង ដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ពីភាគីនោះ។ (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាល *លេខ ១២២/១០-ម៉េង យ៉ាន់)* ។

តាមរយៈអង្គហេតុ កម្មករនិយោជិតដែលមិនមែនជាសមាជិករបស់សហជីពយុវជនខ្មែរ ពុំមានវត្តមាននៅក្នុងសវនាការ ដើម្បីធ្វើការទាមទារទេ ហើយភាគីសហជីពយុវជនខ្មែរដែលបានទាមទារចំណុចវិវាទនេះ ក៏ពុំបានដាក់លិខិតផ្ទេរសិទ្ធិរបស់កម្មករនិយោជិតទាំងនោះ មកក្រុមប្រឹក្សាអាជ្ញាកណ្ដាលដែរ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាតែកម្មករនិយោជិត ដែលជាសមាជិករបស់សហជីពយុវជនខ្មែរប៉ុណ្ណោះ។

មាត្រា ១១៦ នៃច្បាប់ពីការងារបានចែងថា *" ប្រាក់ឈ្នួលនៃកម្មករ ត្រូវបើកយ៉ាងហោចណាស់ពីរដងក្នុងមួយខែ ដោយមានចន្លោះពេលយ៉ាងច្រើនដប់ប្រាំមួយថ្ងៃ។ ប្រាក់ឈ្នួលនៃនិយោជិតត្រូវបើកយ៉ាងហោចណាស់មួយដងក្នុងមួយខែ...... "*។

ផ្អែកលើមាត្រាខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា **ប្រាក់ឈ្នួលនៃកម្មករ** ត្រូវបើកយ៉ាងហោចណាស់ ពីរដងក្នុងមួយខែ ចំណែកឯ**ប្រាក់ឈ្នួលនៃនិយោជិត** ត្រូវបើកយ៉ាងហោចណាស់ មួយដងក្នុងមួយខែ។ ច្បាប់ស្តីពីការងារបានកំណត់តែពេលវេលានៃការបើកប្រាក់ឈ្នួលតែប៉ុណ្ណោះ។

ប៉ុន្តែ ក្នុងករណីនេះ កម្មករនិយោជិតបានទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយ ធ្វើការបន្ថែមម៉ោងមួយថ្ងៃម្តង ពោលគឺបើកនៅរៀងរាល់ថ្ងៃ (រៀងរាល់ពេល) ដែលនិយោជកមានការបន្ថែមម៉ោង។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើពិចារណាថា តើប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ជាប្រាក់ឈ្នួលដែរឬទេ ហើយកម្មករនិយោជិតអាចបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងជារៀងរាល់ សម្រាប់ធ្វើការបន្ថែមម៉ោងដែរ ឬទេ?

មាត្រា១០៣ នៃច្បាប់ស្តីពីការងារចែងថា *"ប្រាក់ឈ្នួលមានជាអាទិ៍ដូចតទៅ :*

- *ប្រាក់ឈ្នួលសុទ្ធសាធ*
- *ប្រាក់ម៉ោងបន្ថែម*
- *កំរៃជើងសា*
- *បុព្វលាភ និងប្រាក់បំណាច់..."* ។

តាមខ្លឹមសារមាត្រា ១០៣ កថាខណ្ឌទី១ ចំណុចទី២ នៃច្បាប់ស្តីពីការងារខាងលើ ប្រាក់ម៉ោងបន្ថែមជាផ្នែកមួយនៃប្រាក់ឈ្នួល។ ដូចនេះ កម្មករនិយោជិតអាចទទួលបានប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង តែក្នុងករណីដែលកម្មករនិយោជិតធ្វើការបន្ថែមម៉ោងប៉ុណ្ណោះ។ ដោយសារតែប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងនេះ មានទំនាក់ទំនងជាមួយប្រាក់ម៉ោងបន្ថែម។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង អាចជាផ្នែកនៃប្រាក់ម៉ោងបន្ថែមដែរ ឬទេ?

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មិនមែនជាផ្នែកនៃប្រាក់ម៉ោងបន្ថែមទេ ពីព្រោះប្រាក់នេះជាប្រាក់ជំនួសថ្លៃបាយ វាមិនមែនជាកម្រៃ ដែលបានមកពីការងារបន្ថែមម៉ោងនោះទេ។ ប្រសិនបើនិយោជកមិនផ្តល់ប្រាក់ថ្លៃបាយនេះទេ និយោជកមានកាតព្វកិច្ចត្រូវផ្តល់បាយមួយពេល ដោយឥតគិតថ្លៃដែរ។ ដូច្នេះ ការផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មិនមានទំនាក់ទំនងជាមួយនឹងការផ្តល់ប្រាក់ឈ្នួលម៉ោងបន្ថែម ពេលធ្វើការងារបន្ថែមម៉ោងនោះទេ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ១៧/១០-ហ្សុងខិច ហ្គាមេន ហេតុផលចំណុចវិវាទទី១*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅតាមការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ គឺប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ជាប្រាក់ជំនួសថ្លៃបាយ មិនមែនជាកម្រៃដែលបានមកពីការងារបន្ថែមម៉ោងនោះទេ។

ចំណុចទី៤ សេចក្តីជូនដំណឹងលេខ ០៤៩/១០ កប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០ បានចែងថា *"អត្ថប្រយោជន៍ផ្សេងទៀត ដែលកម្មករនិយោជិតធ្លាប់បាន*

THE ARBITRATION COUNCIL

*ទទួលតាមសេចក្តីជូនដំណឹងលេខ ០១៧ សកបយ. ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ត្រង់ចំណុចទី៣, ទី៤, ទី៥ និងទី៦ ត្រូវរក្សាទុក និងមានសុពលភាពអនុវត្តដដែល ។"*

ចំណុចទី៤ នៃសេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ ចែងថា *" កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងតាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ១០០០ រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេល ដោយឥតគិតថ្លៃ "* ។

នៅក្នុងសំណុំរឿង ១៧/១០-ហ្សុងចិច ហ្គាមេន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ការផ្តល់បាយមួយពេលនេះ គឺជាការផ្តល់កម្លាំងបន្ថែមទៀត ដើម្បីធ្វើការបន្ថែមម៉ោង បន្ទាប់ពីចប់ម៉ោងធ្វើការធម្មតា ដែលត្រូវបន្តទៅម៉ោងខាងមុខទៀត ពីព្រោះថា បាយ គឺជាតម្រូវការចាំបាច់ប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប ដែលមិនអាចអត់បាន ហើយដែលនិយោជកត្រូវតែផ្តល់ឱ្យ ។ ហេតុនេះ ទោះបីជានិយោជកមិនអាចផ្តល់បាយ ឱ្យកម្មករនិយោជិតនៅពេលធ្វើការបន្ថែមម៉ោង ក៏សេចក្តីជូនដំណឹងលេខ ០១៧ សកបយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ បានកំណត់ឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយជំនួសការផ្តល់បាយដោយឥតគិតថ្លៃ ឬក៏និយោជកផ្តល់ជាប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ១០០០ រៀល ក្នុងមួយថ្ងៃ ដែរ ។

យោងតាមសេចក្តីជូនដំណឹង និងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលខាងលើ និយោជកមានកាតព្វកិច្ច ត្រូវផ្តល់បាយមួយពេល ដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការងារបន្ថែមម៉ោង ព្រោះបាយមួយពេលនេះ គឺជាការផ្តល់កម្លាំងបន្ថែមទៀត ដើម្បីធ្វើការបន្ថែមម៉ោង ។ ប៉ុន្តែ ក្នុងករណីនេះ ក្រុមប្រឹក្សាកណ្តាល យល់ឃើញថា សេចក្តីជូនដំណឹងនេះ ពុំបានបញ្ជាក់អំពីពេលវេលានៃការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងនេះទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បានយល់ឃើញថា ការផ្តល់ជូនបាយមួយពេល ដោយឥតគិតថ្លៃ គឺត្រូវតែធ្វើឡើងជារៀងរាល់ថ្ងៃធ្វើការបន្ថែមម៉ោង ។ ដូច្នេះ វាមានលក្ខណៈសមហេតុផល ដែលប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ត្រូវបើកជូនឱ្យកម្មករនិយោជិតរៀងរាល់ថ្ងៃដែរ ។ *( សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤៧/០៧-ជុង ហ្វៃ ហេតុផលចំណុចវិវាទទី៥, លេខ ៧៩/០៧-តេរ៉ាតិច្ស ហេតុផលចំណុចវិវាទទី៥, លេខ ៨៥/០៩-ណាន់ឝ័ង ហេតុផលចំណុចវិវាទទី១០ និងលេខ ១៧/១០-ហ្សុងចិច ហ្គាមេន ហេតុផលចំណុចវិវាទទី១)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ដល់កម្មករនិយោជិតត្រូវធ្វើឡើងក្នុងរយៈពេលមួយសមស្រប ដែលត្រូវធានាថា កម្មករនិយោជិតអាចមានប្រាក់ទិញបាយសម្រាប់ហូបពេលធ្វើការបន្ថែមម៉ោង ។ ដូចនេះ ការបើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង អាចធ្វើឡើងជារៀងរាល់ថ្ងៃ ឬជារៀងរាល់សប្តាហ៍ ឬជារៀងរាល់ខែបាន ឱ្យតែកម្មករនិយោជិតអាចមានលទ្ធភាពចាត់ចែងប្រាក់នោះ សម្រាប់ទិញបាយហូប ពេលធ្វើការបន្ថែមម៉ោងបាន ។

THE ARBITRATION COUNCIL

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតបានទាមទារឱ្យនិយោជកបើកប្រាក់ថ្លៃបាយ សម្រាប់ធ្វើការបន្ថែមម៉ោងនេះ ក្នុងមួយថ្ងៃម្តង ដោយមានមូលហេតុថា កម្មករនិយោជិត ត្រូវការប្រាក់មកផ្គត់ផ្គង់សម្រាប់ទិញអាហារមកបរិភោគ នៅពេលធ្វើការបន្ថែមម៉ោងទេ។ បើយោងតាមផ្លូវច្បាប់ គឺតម្រូវឱ្យនិយោជកបើកប្រាក់ថ្លៃបាយនេះ ជារៀងរាល់ថ្ងៃ ព្រោះកម្មករនិយោជិតត្រូវការបរិភោគបាយជារៀងរាល់ថ្ងៃ។ ម្យ៉ាងទៀត កម្មករនិយោជិតមានជីវភាពខ្វះខាត ពុំមានប្រាក់គ្រប់គ្រាន់ សម្រាប់ទិញអាហារបរិភោគទេ ពេលខ្លះ ពួកគាត់អាចឈឺ អាចសន្លប់ ឬខ្យល់គ នៅពេលកំពុងធ្វើការ ដោយសារខ្វះជីវជាតិ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅក្នុងក្រុមហ៊ុនមានការបន្ថែមម៉ោងជារៀងរាល់ថ្ងៃ ដោយចាប់បន្តធ្វើការ ពីម៉ោង ៤:០០ ដល់ម៉ោង ៦:០០ ល្ងាច។ ដូចនេះ កម្មករនិយោជិត ត្រូវការកម្លាំង និងថាមពលបន្ថែមទៀត ដើម្បីបំពេញការងារឱ្យបានល្អ ជូននិយោជក។ ក្នុងករណីនេះ កម្មករនិយោជិតពុំមានលទ្ធភាព និងប្រាក់ដើម្បីទៅទិញបាយ (អាហារ) ហូបសម្រាប់បន្តធ្វើការបន្ថែមម៉ោងនោះ ជារៀងរាល់ថ្ងៃទេ។ ហេតុដូចនេះហើយទើបពួកគាត់ស្នើសុំទៅនិយោជក ឱ្យបើកប្រាក់ថ្លៃបាយនេះ ជូនជារៀងរាល់ពេល ដែលមានការបន្ថែមម៉ោង។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត ត្រូវការបរិភោគបាយ ជារៀងរាល់ថ្ងៃ។ ដូចនេះពួកគាត់ត្រូវការប្រាក់ដើម្បីយកទៅទិញបាយហូបជារៀងរាល់ថ្ងៃដែរ។ ចំពោះករណីដែលនិយោជកលើកឡើងថា និយោជកពុំមានបុគ្គលិកគ្រប់គ្រាន់ ដើម្បីមករៀបចំបើកប្រាក់ថ្លៃបាយជារៀងរាល់ថ្ងៃជូនកម្មករនិយោជិតបាន ហើយប្រពន្ធ័គណនេយ្យរបស់ក្រុមហ៊ុន បានបញ្ចូលប្រាក់ឈ្នួល និងប្រាក់ថ្លៃបាយបន្ថែមម៉ោងនេះ ជាមួយគ្នាតែម្តងនោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វាអាចជាមានការលំបាក និងអាចជាបន្ទុកដល់និយោជកក្នុងការរៀបចំប្រាក់ថ្លៃបាយនេះប្រាកដមែន ព្រោះការបន្ថែមម៉ោងនេះ មានជារៀងរាល់ថ្ងៃ ហើយកម្មករនិយោជិតមានចំនួនច្រើនគឺប្រហែលជា ២២០០ នាក់។ ដូចនេះ និយោជកត្រូវចំណាយថ្លៃជួលបុគ្គលិកបន្ថែម ឬចំណាយប្រាក់ដើម្បីធ្វើការកែប្រែប្រពន្ធ័គណនេយ្យរបស់ខ្លួនឡើងវិញទៀត។ ប៉ុន្តែ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថាបញ្ហាដែលកម្មករនិយោជិតកំពុងជួបប្រទះនេះ វាមានសភាពបន្ទាន់ ហើយធ្ងន់ធ្ងរជាង ហើយនិយោជកគួរតែធ្វើការដោះស្រាយជូនពួកគាត់ភ្លាមៗ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកអាចមានលទ្ធភាពធ្វើការបន្ថែមចំនួនបុគ្គលិក ឬអាចធ្វើការកែប្រែប្រពន្ធ័គណនេយ្យនេះ ដើម្បីសម្រួលដល់ផលលំបាកដែលកម្មករនិយោជិតរបស់ខ្លួនកំពុងជួបប្រទះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ថ្វីត្បិតតែនិយោជកត្រូវចំណាយថវិកាបន្តិចមែន ប៉ុន្តែ បើនិយោជកអាចដោះស្រាយបញ្ហាជូនកម្មករនិយោជិតបាន ក៏ដូចជានិយោជកជួយបង្កើនទិន្នផលការងាររបស់ខ្លួន និងទទួលបានប្រាក់ចំណូលខ្ពស់សម្រាប់ក្រុមហ៊ុនដែរ ព្រោះថា បើកម្មករនិយោជិតមានប្រាក់គ្រប់គ្រាន់ ដើម្បីយកទៅទិញបាយហូបនៅពេលមានការងារបន្ថែមម៉ោងនោះ កម្មករនិយោជិតនឹងមានកម្លាំងគ្រប់គ្រាន់ ហើយមានកំលាំងចិត្តខិតខំធ្វើការងារឱ្យបានល្អជូននិយោជកវិញដែរ។ កត្តាទាំងអស់នេះ គឺជាការស្មើ

THE ARBITRATION COUNCIL

ទានទៅវិញទៅមក រវាងកម្មករនិយោជិត និងនិយោជក ដើម្បីធានាឱ្យបាននូវទំនាក់ទំនង នៅទីកន្លែងធ្វើការរបស់ខ្លួនមានសភាពល្អប្រសើរ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចឱ្យនិយោជក បើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មួយថ្ងៃម្តង ដល់កម្មករនិយោជិតដែលជាសមាជិករបស់សហជីពយុវជនខ្មែរ នៅពេលពួកគាត់ស្ម័គ្រចិត្តធ្វើការងារបន្ថែមម៉ោង ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ :

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ :** បង្គាប់ឱ្យនិយោជក បើកប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង មួយថ្ងៃម្តង ដល់កម្មករនិយោជិតដែលជាសមាជិករបស់សហជីពយុវជនខ្មែរ នៅពេលពួកគាត់ស្ម័គ្រចិត្តធ្វើការងារបន្ថែមម៉ោង ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **សេង ទួចហ៊ុន**

ហត្ថលេខា: ------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **វ៉ែន ពៅ**

ហត្ថលេខា: ------------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **ប៉ែន ប៊ុនឈា**

ហត្ថលេខា: ------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL